# គោលការណ៍ណែនាំសំរាប់អនុវត្តមាត្រា ៥.៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ដើម្បីការពារគោលនយោបាយសុខភាពសាធារណៈទាក់ទងទៅនឹងការត្រួតពិនិត្យថ្នាំជក់ ប្រឆាំងនឹងផលប្រយោជន៍ពាណិជ្ជកម្ម និងផលប្រយោជន៍ផ្សេងទៀតរបស់ឧស្សាហកម្មថ្នាំជក់

## បុព្វយោគ

១. សេចក្តីសំរេចចិត្តរបស់សន្និបាតសុខភាពពិភពលោក (WHA 54.18) ស្តីពីតម្លាភាពក្នុងវិធីត្រួតពិនិត្យថ្នាំជក់ ដោយផ្អែកទៅលើការរកឃើញឯកសាររបស់ឧស្សាហកម្មថ្នាំជក់ របស់គណៈកម្មការជំនាញថែងថា " ឧស្សាហកម្ម ថ្នាំជក់ រាប់ឆ្នាំមកហើយ បានប្រតិបត្តិដោយចេតនា ក្នុងការធ្វើឱ្យទន់ខ្សោយដល់តួនាទីរបស់រដ្ឋាភិបាល និងរបស់អង្គការសុខភាពពិភពលោក ដើម្បីអនុវត្តគោលនយោបាយសុខភាពសាធារណៈ ប្រយុទ្ធប្រឆាំងទៅនឹងការរីករាលដាលនៃថ្នាំជក់។

២. បុព្វកថានៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ របស់អង្គការសុខភាពពិភពលោក ចង្អុលបង្ហាញថា ភាគីទាំងឡាយ "ត្រូវរំលឹកប្រាប់ជាមុនឱ្យប្រុងប្រយ័ត្នចំពោះការខិតខំរបស់ឧស្សាហកម្មថ្នាំជក់ ដើម្បីបំផ្លិចបំផ្លាញ និងវិទ្ធង្សនាចំពោះការខិតខំត្រួតពិនិត្យថ្នាំជក់ ហើយនិងតម្រូវការចំពោះការទទួលព័ត៌មាន អំពីសកម្មភាពរបស់ឧស្សាហកម្មថ្នាំជក់ ដែលមានផលប៉ះពាល់ជាអវិជ្ជមានដល់ការខិតខំត្រួតពិនិត្យថ្នាំជក់"។

៣. លើសពីនេះទៀត មាត្រា ៥.៣ នៃអនុសញ្ញានេះ ទាមទារ " នៅក្នុងការកំណត់ និងការអភិវឌ្ឍន៍គោលនយោបាយសុខភាពសាធារណៈទាក់ទងដល់ការត្រួតពិនិត្យថ្នាំជក់ ភាគីទាំងឡាយត្រូវធ្វើយ៉ាងណាដើម្បីការពារនូវគោលនយោបាយទាំងនោះ ប្រឆាំងនឹងផលប្រយោជន៍ពាណិជ្ជកម្ម ឬផលប្រយោជន៍ផ្សេងទៀត របស់ឧស្សាហកម្មថ្នាំជក់ ស្របតាមច្បាប់របស់ជាតិ។

៤. សេចក្តីសំរេចរបស់សន្និសីទភាគី (FCTC/COP2-14) បានបង្កើតក្រុមការងារមួយ ដើម្បីពិនិត្យបង្កើតគោលការណ៍ណែនាំសំរាប់អនុវត្តមាត្រ ៥.៣ នៃអនុសញ្ញានេះ។

៥. ដោយមិនធ្វើឱ្យខូចខាតដល់សិទ្ធិអធិបតេយ្យភាពនៃភាគីទាំងឡាយ ក្នុងការកំណត់ និងបង្កើតគោលនយោបាយត្រួតពិនិត្យថ្នាំជក់ ភាគីទាំងឡាយត្រូវបានលើកទឹកចិត្តឱ្យអនុវត្តគោលការណ៍ទាំងនេះ ឱ្យបានច្រើនតាមដែលអាចធ្វើបាន ស្របតាមច្បាប់របស់ជាតិ។

## គោលបំណង វិសាលភាព និងភាពអាចអនុវត្តបាន

៦. ប្រើប្រាស់គោលការណ៍ណែនាំសំរាប់អនុវត្តមាត្រា ៥.៣ នៃអនុសញ្ញានេះ នឹងមានផលច្រើនទៅលើគោលនយោបាយត្រួតពិនិត្យថ្នាំជក់ និងទៅលើការអនុវត្តន៍អនុសញ្ញា ព្រោះគោលការណ៍ណែនាំទាំងនេះទទួលស្គាល់ថា ការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ រួមទាំងឧស្សាហកម្មថ្នាំជក់របស់រដ្ឋផង កាត់បន្ថយវិស័យជាច្រើន នៃគោលនយោបាយត្រួតពិនិត្យថ្នាំជក់ ដូចមានចែងក្នុងបុព្វកថានៃអនុសញ្ញានេះ

ក្នុងមាត្រា ដែលទាក់ទងទៅនឹងគោលនយោបាយត្រួតពិនិត្យថ្នាំជក់ដាច់ដោយឡែក និងការគ្រប់គ្រង នីតិវិធី នៃអនុសញ្ញាស្ដីពីការត្រួតពិនិត្យថ្នាំជក់។

៧. គោលបំណងនៃគោលការណ៍ណែនាំទាំងនេះ គឺដើម្បីធានាថា រាល់ការខិតខំដើម្បីការពារការត្រួតពិនិត្យថ្នាំជក់ ប្រឆាំងនឹងផលប្រយោជន៍ពាណិជ្ជកម្ម និងផលប្រយោជន៍ដទៃទៀតរបស់ឧស្សាហកម្មថ្នាំជក់ មានភាពទូលំទូលាយ និងមានប្រសិទ្ធភាព។ ភាគីទាំងឡាយ គួរអនុវត្តវិធានការទាំងនេះ នៅគ្រប់ផ្នែករបស់រដ្ឋាភិបាល ដែលអាចនឹងមានផលប្រយោជន៍ ឬសមត្ថភាព នៅក្នុងការធ្វើឱ្យប៉ះពាល់ដល់គោលនយោបាយសុខភាពសាធារណៈ ទាក់ទងទៅនឹងការត្រួតពិនិត្យថ្នាំជក់។

៨. បំណងប្រាថ្នានៃគោលការណ៍ណែនាំទាំងនេះ គឺដើម្បីជួយដល់ភាគីទាំងឡាយ ដើម្បីបំពេញកាតព្វកិច្ចនៃមាត្រា ៥.៣ របស់អនុសញ្ញា។ គោលការណ៍ណែនាំទាំងនេះ ប្រើប្រាស់ភស្តុតាងវិទ្យាសាស្ត្រល្អបំផុតដែលមាន និងបទពិសោធន៍របស់ភាគីទាំងឡាយ នៅក្នុងការបរិយាយអំពីការជ្រៀតជ្រែក របស់ឧស្សាហកម្មថ្នាំជក់។

៩. គោលការណ៍ណែនាំទាំងនេះ អនុវត្តចំពោះការបង្កើត និងការអនុវត្តន៍គោលនយោបាយសុខភាពសាធារណៈ ទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ របស់ភាគីទាំងឡាយ។ គោលការណ៍ណែនាំទាំងនេះក៏អនុវត្តជាមួយបុគ្គល ស្ថាប័ន ឬអង្គភាព ដែលរួមចំណែក ឬអាចរួមចំណែកក្នុងការតាក់តែង អនុវត្តចាត់ចែង និងពង្រឹងគោលនយោបាយទាំងនេះ។

១០. គោលការណ៍ណែនាំទាំងនេះ អនុវត្តចំពោះមន្ត្រីរដ្ឋាភិបាល តំណាង ឬនិយោជិក នៃស្ថាប័នជាតិ រដ្ឋ ខេត្ត ក្រុង មូលដ្ឋាន ឬស្ថាប័នសាធារណៈដទៃទៀត ឬស្ថាប័នពាក់កណ្ដាលសាធារណៈ ឬអង្គភាពស្ថិតក្នុងអំណាចរបស់ភាគីមួយ និងចំពោះបុគ្គលណាដែលប្រតិបត្តិក្នុងនាមបុគ្គលទាំងឡាយនេះ។ គ្រប់ផ្នែករបស់រដ្ឋាភិបាល (នីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ) ដែលទទួលខុសត្រូវក្នុងការបង្កើត និងអនុវត្តន៍គោលនយោបាយត្រួតពិនិត្យថ្នាំជក់ និងក្នុងការការពារគោលនយោបាយទាំងនេះ ប្រឆាំងនឹងផលប្រយោជន៍ឧស្សាហកម្មថ្នាំជក់ គួរតែត្រូវបានរាប់បញ្ចូល។

១១. វិធីសាស្ត្រដ៏ទូលំទូលាយនៃយុទ្ធសាស្ត្រ និងកលល្បិច ដែលប្រើប្រាស់ដោយឧស្សាហកម្មថ្នាំជក់ ដើម្បីជ្រៀតជ្រែកទៅក្នុងការបង្កើត និងអនុវត្តន៍វិធានការត្រួតពិនិត្យថ្នាំជក់ ដែលភាគីទាំងឡាយត្រូវអនុវត្តត្រូវបានចងក្រងជាឯកសារដោយមានភស្តុតាងយ៉ាងច្រើន។ វិធានការដែលទាមទារដោយគោលការណ៍ណែនាំទាំងនេះ មានគោលបំណងទប់ស្កាត់ប្រឆាំងនឹងការជ្រៀតជ្រែក មិនត្រឹមតែដោយឧស្សាហកម្មថ្នាំជក់ផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយស្ថាប័ន ឬបុគ្គលទាំងឡាយណា ដែលបំរើឱ្យផលប្រយោជន៍របស់ឧស្សាហកម្មថ្នាំជក់។

១២. វិធានការដែលមានចែងក្នុងគោលការណ៍ណែនាំទាំងនេះ គួរតែអនុវត្តចំពោះភាគីទាំងឡាយ ឱ្យបានទូលំទូលាយតាមដែលអាចធ្វើបាន។ ដើម្បីឈានសំរេចឱ្យបានខ្ពស់បំផុត គោលបំណងនៃមាត្រា ៥.៣ របស់

អនុសញ្ញា ភាគីទាំងឡាយត្រូវបានលើកទឹកចិត្តខ្លាំងក្លាបំផុត ឱ្យអនុវត្តវិធានការលើសពីអនុសាសន៍ ដែលមានក្នុងគោលការណ៍ណែនាំទាំងនេះ ទៅតាមកាលៈទេសៈដាច់ដោយឡែក ។

## គោលការណ៍ណែនាំ

**គោលការណ៍ទី១: ឧស្សាហកម្មថ្នាំជក់ និងសុខភាពសាធារណៈ មានទំនាស់ផលប្រយោជន៍ជាមូលដ្ឋាន ដែលមិនអាចផ្សះផ្សារគ្នាបាន ។**

១៣. ឧស្សាហកម្មថ្នាំជក់ ផលិតនិងផ្សព្វផ្សាយលក់ផលិតផលមួយ ដែលបញ្ជាក់ដោយវិទ្យាសាស្ត្រថា ញៀន បណ្តាលឱ្យអ្នកប្រើប្រាស់កើតជំងឺ និងស្លាប់បាត់បង់ជីវិត ព្រមទាំងបង្កើនភាពក្រីក្រដល់សង្គម។ ដូច្នេះ ភាគីទាំងឡាយ គួរការពារការតាក់តែង និងការអនុវត្តន៍គោលនយោបាយសាធារណៈ សំរាប់ត្រួតពិនិត្យថ្នាំជក់ ប្រឆាំងនឹងឧស្សាហកម្មថ្នាំជក់ ដល់កំរិតអតិបរមាដែលអាចធ្វើបាន ។

**គោលការណ៍ទី២: ភាគីទាំងឡាយ គួរតែមានការទទួលខុសត្រូវ និងតម្លាភាព នៅពេលដោះស្រាយជាមួយឧស្សាហកម្មថ្នាំជក់ ឬជាមួយស្ថាប័នដែលធ្វើការបំរើផលប្រយោជន៍ឧស្សាហកម្មថ្នាំជក់ ។**

១៤. ភាគីទាំងឡាយ គួរធានាថា ទំនាក់ទំនងណាមួយជាមួយឧស្សាហកម្មថ្នាំជក់ ទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ ឬសុខភាពសាធារណៈ ត្រូវមានការទទួលខុសត្រូវ និងតម្លាភាព ។

**គោលការណ៍ទី៣: ភាគីទាំងឡាយ គួរទាមទារឱ្យឧស្សាហកម្មថ្នាំជក់ និងស្ថាប័នដែលធ្វើការបំរើផលប្រយោជន៍របស់ឧស្សាហកម្មថ្នាំជក់ ប្រតិបត្តិ និងធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ និងតម្លាភាព ។**

១៥. ឧស្សាហកម្មថ្នាំជក់ គួរតែត្រូវបានទាមទារឱ្យផ្តល់ដល់ភាគីទាំងឡាយ នូវព័ត៌មានទាំងឡាយដើម្បីអនុវត្តគោលការណ៍ណែនាំទាំងនេះ ឱ្យមានប្រសិទ្ធភាព ។

**គោលការណ៍ទី៤: ដោយសារថ្នាំជក់ជាផលិតផល ដែលបណ្តាលឱ្យអ្នកប្រើប្រាស់ស្លាប់បាត់បង់ជីវិត ឧស្សាហកម្មថ្នាំជក់ មិនគួរទទួលបាននូវការលើកទឹកចិត្តដើម្បីបង្កើត ឬប្រតិបត្តិជំនួញរបស់ពួកគេឡើយ ។**

១៦. ការប្រព្រឹត្តដោយចូលចិត្តចំពោះឧស្សាហកម្មថ្នាំជក់ នឹងជាទំនាស់ជាមួយគោលនយោបាយត្រួតពិនិត្យថ្នាំជក់ ។

## អនុសាសន៍

១៧. សកម្មភាពសំខាន់ៗដូចខាងក្រោមនេះ ត្រូវបានផ្ដល់អនុសាសន៍ ដើម្បីដោះស្រាយការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ នៅក្នុងគោលនយោបាយសុខភាពសាធារណៈ

(១) ផ្ដល់ការយល់ដឹងអំពីការញៀន និងការផ្ដល់គ្រោះថ្នាក់របស់ផលិតផលថ្នាំជក់ និងអំពីការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ ប្រឆាំងនឹងគោលនយោបាយត្រួតពិនិត្យថ្នាំជក់ របស់ភាគីទាំងឡាយ ។

(២) បង្កើតវិធានការ ដើម្បីកាត់បន្ថយទំនាក់ទំនងជាមួយឧស្សាហកម្មថ្នាំជក់ និងដើម្បីធានានូវតម្លាភាព នៃទំនាក់ទំនងដែលបានកើតឡើង ។

(៣) បដិសេធភាពជាដៃគូ និងកិច្ចព្រមព្រៀងដែលមិនអាចចងក្រងបាន ឬមិនអាចពង្រឹងបាន ជាមួយឧស្សាហកម្មថ្នាំជក់ ។

(៤) ចៀសវាងទំនាស់ផលប្រយោជន៍ សំរាប់មន្ត្រី និងនិយោជិករដ្ឋាភិបាល ។

(៥) ទាមទារព័ត៌មានដែលផ្ដល់ដោយឧស្សាហកម្មថ្នាំជក់ មានតម្លាភាព និងត្រឹមត្រូវ ។

(៦) ប្រែក្លាយជាមិនធម្មតា និងដាក់កំរិតតាមដែលអាចធ្វើបាន សកម្មភាពដែលឧស្សាហកម្មថ្នាំជក់ហៅថា "ការទទួលខុសត្រូវចំពោះសង្គម" ដោយរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមសកម្មភាពដែលហៅថា "ការទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុន" ។

(៧) មិនត្រូវផ្ដល់ការប្រព្រឹត្តដោយចូលចិត្ត ចំពោះឧស្សាហកម្មថ្នាំជក់ទេ ។

(៨) ប្រព្រឹត្តដូចគ្នា ចំពោះឧស្សាហកម្មថ្នាំជក់របស់រដ្ឋ និងឧស្សាហកម្មថ្នាំជក់ដទៃទៀត ។

១៨. វិធានការដែលបានយល់ព្រម ដើម្បីការពារគោលនយោបាយសុខភាពសាធារណៈ ទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ ប្រឆាំងនឹងផលប្រយោជន៍ពាណិជ្ជកម្ម និងផលប្រយោជន៍ដទៃទៀតរបស់ឧស្សាហកម្មថ្នាំជក់ ត្រូវបានចែងដូចខាងក្រោម ។ ភាគីទាំងឡាយ ត្រូវបានលើកទឹកចិត្តឱ្យអនុវត្តវិធានការនានាលើសពីវិធានការទាំងឡាយដែលបានចែងក្នុងគោលការណ៍ណែនាំទាំងនេះ ហើយគ្មានអ្វីដែលបានចែងក្នុងគោលការណ៍ណែនាំទាំងនេះ ត្រូវរាំងស្កាត់មិនឱ្យភាគីទាំងឡាយ ដាក់លក្ខខ័ណ្ឌតឹងរឹងបន្ថែមទៀតដែលស្របទៅនឹងអនុសាសន៍ទាំងនេះ ។

### (១) ផ្ដល់ការយល់ដឹងអំពីការញៀន និងការផ្ដល់គ្រោះថ្នាក់របស់ផលិតផលថ្នាំជក់ និងអំពីការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ ប្រឆាំងនឹងគោលនយោបាយត្រួតពិនិត្យថ្នាំជក់ របស់ភាគីទាំងឡាយ ។

១៩. គ្រប់ផ្នែករបស់រដ្ឋាភិបាល និងរបស់សាធារណៈ ត្រូវការចំណេះដឹង និងការយល់ដឹងអំពីការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់កាលពីអតីតកាល និងពេលបច្ចុប្បន្ន នៅក្នុងការបង្កើត និងអនុវត្តន៍គោលនយោ

បាយសាធារណៈទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់។ ការជ្រើតជ្រែកទាំងនេះ ទាមទារឱ្យមានសកម្មភាពដាច់ដោយឡែក ដើម្បីអនុវត្តឱ្យបានជោគជ័យ អនុសញ្ញាទាំងមូល។

**អនុសាសន៍**

១.១ ភាគីទាំងឡាយ ដោយផ្អែកលើមាត្រា ១២ នៃអនុសញ្ញា ជូនដំណឹង និងអប់រំដល់គ្រប់ផ្នែករបស់រដ្ឋាភិបាល និងសាធារណៈ អំពីការញៀន និងការផ្តល់គ្រោះថ្នាក់របស់ផលិតផលថ្នាំជក់ និងអំពីសេចក្តីត្រូវការ ក្នុងការការពារគោលនយោបាយសុខភាពសាធារណៈ ទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ ប្រឆាំងនឹងផលប្រយោជន៍ពាណិជ្ជកម្ម និងផលប្រយោជន៍ដទៃទៀតរបស់ឧស្សាហកម្មថ្នាំជក់ ព្រមទាំងយុទ្ធសាស្ត្រ និងកលល្បិចរបស់ឧស្សាហកម្មថ្នាំជក់ ក្នុងការជ្រៀតជ្រែកទៅក្នុងការបង្កើត និងអនុវត្តន៍ គោលនយោបាយសុខភាពសាធារណៈ ទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់។

១.២ លើសពីនេះទៀត ភាគីទាំងឡាយគួរផ្តល់ការយល់ដឹងអំពីការប្រព្រឹត្តរបស់ឧស្សាហកម្មថ្នាំជក់ ដោយប្រើប្រាស់បុគ្គល ក្រុមជួរមុខ និងស្ថាប័នដែលពាក់ព័ន្ធ ឱ្យប្រព្រឹត្តក្នុងនាមខ្លួន ឬក៏ធ្វើសកម្មភាព ដើម្បីបំរើផលប្រយោជន៍បន្ថែមរបស់ឧស្សាហកម្មថ្នាំជក់ ដោយបើកចំហ ឬដោយសំងាត់។

**(២) បង្កើតវិធានការ ដើម្បីកាត់បន្ថយទំនាក់ទំនងជាមួយឧស្សាហកម្មថ្នាំជក់ និងដើម្បីធានាឱ្យតម្លាភាព នៃទំនាក់ទំនងដែលបានកើតឡើង។**

២០. នៅក្នុងការបង្កើត និងអនុវត្តន៍គោលនយោបាយសុខភាពសាធារណៈ ទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ ទំនាក់ទំនងចាំបាច់ណាមួយជាមួយឧស្សាហកម្មថ្នាំជក់ គួរតែធ្វើឡើងដោយភាគីទាំងឡាយ ក្នុងមធ្យោបាយ ដើម្បីចៀសវាងការបង្កើតការយល់ច្រឡំណាមួយនៃភាពជាដៃគូពិតប្រាកដ ឬពោរពេញដោយសក្តានុពល ដែលជាលទ្ធផល ឬជាប្រយោជន៍នៃទំនាក់ទំនងទាំងនេះ។ នៅក្នុងព្រឹត្តិការណ៍ ដែលឧស្សាហកម្មថ្នាំជក់ ជាប់ទាក់ទងទៅនឹងការប្រព្រឹត្តណាមួយដែលអាចបង្កើតជាការយល់ច្រលំនេះ ភាគីទាំងឡាយ គួរធ្វើសកម្មភាពដើម្បីការពារ ឬកែប្រែការយល់ច្រឡំនេះ។

**អនុសាសន៍**

២.១ ភាគីទាំងឡាយ គួរមានទំនាក់ទំនងជាមួយឧស្សាហកម្មថ្នាំជក់ តែក្នុងពេលណាដែលអាចដាក់កំរិត ប្រកបដោយប្រសិទ្ធភាព ចំពោះឧស្សាហកម្មថ្នាំជក់ និងផលិតផលថ្នាំជក់។

២.២ នៅពេលណាដែលទំនាក់ទំនងជាមួយឧស្សាហកម្មថ្នាំជក់ មានភាពចាំបាច់ ភាគីទាំងឡាយគួរធានាថា ទំនាក់ទំនងនេះត្រូវបានធ្វើឡើងប្រកបដោយតម្លាភាព។ បើអាចធ្វើបាន ទំនាក់ទំនងទាំងនេះ គួរតែធ្វើឡើងជាសាធារណៈ ឧទាហរណ៍ ដោយមានសាធារណជនចូលរួមស្តាប់

ការកត់សំគាល់ជាសាធារណៈអំពីទំនាក់ទំនងទាំងនេះ ការផ្សព្វផ្សាយជាសាធារណៈ នូវកំណត់ត្រានៃទំនាក់ទំនងទាំងនេះ។

**(៣) បដិសេធភាពជាដៃគូ និងកិច្ចព្រមព្រៀងដែលមិនអាចចងក្រងបាន ឬមិនអាចពង្រឹងបាន ជាមួយឧស្សាហកម្មថ្នាំជក់។**

២១. ឧស្សាហកម្មថ្នាំជក់ មិនគួរជាដៃគូ នៅក្នុងការផ្តួចផ្តើមណាមួយដើម្បីបង្កើត និងអនុវត្តន៍គោលនយោបាយសាធារណៈ ដោយហេតុថាផលប្រយោជន៍របស់ឧស្សាហកម្មថ្នាំជក់ ទំនាស់ដោយផ្ទាល់ទៅនឹងគោលដៅសុខភាពសាធារណៈ។

**អនុសាសន៍**

៣.១ ភាគីទាំងឡាយ មិនគួរទទួលយក គាំទ្រ ឬព្រមព្រៀងភាពជាដៃគូ ឬកិច្ចព្រមព្រៀងដែលមិនអាចចងក្រងបាន ឬមិនអាចពង្រឹងបាន ព្រមទាំងកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្តណាមួយ ជាមួយឧស្សាហកម្មថ្នាំជក់ ស្ថាប័ន ឬបុគ្គលណាមួយ ដែលធ្វើការបំរើផលប្រយោជន៍របស់ឧស្សាហកម្មថ្នាំជក់។

៣.២ ភាគីទាំងឡាយ មិនគួរទទួលយក គាំទ្រ ឬព្រមព្រៀងការអប់រំសាធារណៈ ការអប់រំយុវវ័យ ឬការផ្តួចផ្តើមទាំងឡាយ ដែលរៀបចំ ផ្សព្វផ្សាយ ចូលរួម ឬអនុវត្តដោយឧស្សាហកម្មថ្នាំជក់ ដែលទាក់ទងដោយផ្ទាល់ ឬមិនផ្ទាល់ជាមួយការត្រួតពិនិត្យថ្នាំជក់។

៣.៣ ភាគីទាំងឡាយ មិនគួរទទួលយក គាំទ្រ ឬព្រមព្រៀងក្រមប្រតិបត្តិដោយស្ម័គ្រចិត្ត ឬលិខិតបទដ្ឋានណាមួយដែលព្រាងដោយឧស្សាហកម្មថ្នាំជក់ ដែលជាញឹកញាប់លិខិតបទដ្ឋានទាំងនេះនឹងប្រើប្រាស់ជំនួសវិធានការត្រួតពិនិត្យថ្នាំជក់ ដែលអាចពង្រឹងតាមផ្លូវច្បាប់បាន។

៣.៤ ភាគីទាំងឡាយ មិនគួរទទួលយក គាំទ្រ ឬព្រមព្រៀងទទួលយកជំនួយណាមួយ ឬច្បាប់ស្តីពីការត្រួតពិនិត្យណាមួយ ឬគោលនយោបាយដែលព្រាងដោយ ឬសហការជាមួយឧស្សាហកម្មថ្នាំជក់ឡើយ។

**(៤) ចៀសវាងទំនាស់ផលប្រយោជន៍ សំរាប់មន្ត្រី និងនិយោជិករដ្ឋាភិបាល។**

២២. ការពាក់ព័ន្ធរបស់អង្គការ ឬបុគ្គលទាំងឡាយ ជាមួយផលប្រយោជន៍ពាណិជ្ជកម្ម ឬផលប្រយោជន៍ដទៃទៀតរបស់ឧស្សាហកម្មថ្នាំជក់ នៅក្នុងគោលនយោបាយសុខភាពសាធារណៈទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ នឹងមានផលអវិជ្ជមាន។ វិន័យជាក់លាក់ទាក់ទិនទៅនឹងទំនាស់ផលប្រយោជន៍ សំរាប់មន្ត្រីនិងនិយោជិករដ្ឋាភិបាលដែលកំពុងបំរើការក្នុងវិស័យត្រួតពិនិត្យថ្នាំជក់ ជាមធ្យោបាយសំខាន់សំរាប់ការពារគោលនយោបាយទាំងនេះ ប្រឆាំងនឹងការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់។

២៣. ជំនូនជាប្រាក់ ជាអំណោយ និងសេវាកម្មទាំងឡាយ ជារូបិយប័ណ្ណ ឬអ្វីៗដូចរូបិយប័ណ្ណ និងការឧបត្ថម្ភថវិកាសំរាប់ការស្រាវជ្រាវ ពីឧស្សាហកម្មថ្នាំជក់ ដល់ស្ថាប័ន មន្ត្រី ឬនិយោជិករដ្ឋាភិបាល អាចបង្កើតជាទំនាស់ផលប្រយោជន៍។ ទំនាស់ផលប្រយោជន៍ ក៏កើតមានដែរ បើសិនមានការសន្យាណាមួយសំរាប់ការពិចារណាដោយអនុគ្រោះទោះជាគ្មានការតបស្នងអ្វីក៏ដោយ ព្រោះសក្កានុពលនេះកើតមានសំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីជះឥទ្ធិពលដល់ការទទួលខុសត្រូវជាផ្លូវការ ដូចដែលបានទទួលស្គាល់ដោយក្រមប្រតិបត្តិសំរាប់អង្គការសហប្រជាជាតិ សំរាប់មន្ត្រីសាធារណៈ និងដោយអង្គការរដ្ឋាភិបាល និងអង្គការសមាហរកម្មសេដ្ឋកិច្ចតំបន់ជាច្រើនទៀត។

**អនុសាសន៍**

៤.១ ភាគីទាំងឡាយគួរមានគោលនយោបាយមួយ ស្តីពីការបង្ហាញ និងការគ្រប់គ្រងទំនាស់ផលប្រយោជន៍ ដែលត្រូវអនុវត្តដោយបុគ្គលគ្រប់រូប ដែលពាក់ព័ន្ធក្នុងការបង្កើត និងអនុវត្តន៍សុខភាពសាធារណៈ ទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ រួមទាំងមន្ត្រី និងនិយោជិករដ្ឋាភិបាល ទីប្រឹក្សា និងមន្ត្រីជាប់កិច្ចសន្យា។

៤.២ ភាគីទាំងឡាយ គួរតែតាក់តែង អនុម័ត និងអនុវត្តក្រមប្រតិបត្តិសំរាប់មន្ត្រីសាធារណៈ ពិពណ៌នាអំពីស្តង់ដា ដែលត្រូវប្រកាន់យកពេលដោះស្រាយជាមួយឧស្សាហកម្មថ្នាំជក់។

៤.៣ ភាគីទាំងឡាយ មិនគួរផ្តល់កិច្ចសន្យា ដល់ការអនុវត្តន៍ការងារបង្កើត និងអនុវត្តន៍គោលនយោបាយសុខភាពសាធារណៈទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ ដល់បេក្ខជនណា ឬអ្នកផ្គត់ផ្គង់ទំនិញ ដែលមានទំនាស់ផលប្រយោជន៍ជាមួយគោលនយោបាយត្រួតពិនិត្យថ្នាំជក់។

៤.៤ ភាគីទាំងឡាយគួរបង្កើតគោលនយោបាយជាក់លាក់ ដែលទាមទារឱ្យអ្នកធ្វើការក្នុងការិយាល័យសាធារណៈទាំងឡាយ ដែលមានតួនាទីនៅក្នុងការបង្កើត និងអនុវត្តន៍គោលនយោបាយសុខភាពសាធារណៈទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ រាយការណ៍ដល់ស្ថាប័នរបស់ខ្លួន អំពីការពាក់ព័ន្ធនៅក្នុងសកម្មភាពធ្វើការងារជាមួយឧស្សាហកម្មថ្នាំជក់ ទោះជាការងារនោះមានលក្ខណៈឈឺចាប់ ឬមិនឈឺចាប់ក៏ដោយ ក្នុងរយៈពេលកំណត់ណាមួយ ក្រោយពីចាកចេញពីការងារនោះ។

៤.៥ ភាគីទាំងឡាយ គួរបង្កើតគោលនយោបាយជាក់លាក់ ទាមទារឱ្យអ្នកបំរើការងារក្នុងការិយាល័យសាធារណៈ ដែលមានតួនាទីក្នុងការបង្កើត និងអនុវត្តន៍គោលនយោបាយសុខភាពសាធារណៈទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ ប្រកាសនូវសកម្មភាពការងាររបស់ខ្លួនជាមួយឧស្សាហកម្មថ្នាំជក់ ក្នុងពេលបច្ចុប្បន្នឬអតីតកាល ទោះជាការងារនោះទទួលបានកំរៃ ឬមិនបានកំរៃក៏ដោយ។

៤.៦ ភាគីទាំងឡាយ គួរទាមទារឱ្យមន្ត្រីរដ្ឋាភិបាល ប្រកាស និងដកខ្លួនចេញពីការទទួលផលប្រយោជន៍ដោយផ្ទាល់ ពីឧស្សាហកម្មថ្នាំជក់។

៤.៧ ស្ថាប័នរដ្ឋាភិបាល និងអង្គភាពរបស់ខ្លួន មិនគួរមានផលប្រយោជន៍ហិរញ្ញវត្ថុណាមួយពីឧស្សាហកម្មថ្នាំជក់ លើកលែងតែមន្ត្រីទាំងនោះ ជាអ្នកទទួលខុសត្រូវចាត់ចែងផលប្រយោជន៍ផ្ទាល់របស់ភាគីទាំងនោះ នៅក្នុងឧស្សាហកម្មថ្នាំជក់របស់រដ្ឋ។

៤.៨ ភាគីទាំងឡាយមិនគួរអនុញ្ញាតឱ្យបុគ្គលណាម្នាក់ ដែលបំរើការឱ្យឧស្សាហកម្មថ្នាំជក់ ឬស្ថាប័នណាមួយ ដែលធ្វើការបំរើផលប្រយោជន៍ឧស្សាហកម្មថ្នាំជក់ ជាសមាជិកនៃអង្គភាព គណៈកម្មការ ក្រុមផ្ដល់យោបល់ណាមួយរបស់រដ្ឋាភិបាល ដែលបង្កើតឡើងដើម្បីអនុវត្តការត្រួតពិនិត្យថ្នាំជក់ ឬគោលនយោបាយសុខភាពសាធារណៈ។

៤.៩ ភាគីទាំងឡាយមិនគួរអនុញ្ញាតឱ្យបុគ្គលណាម្នាក់ ដែលបំរើការឱ្យឧស្សាហកម្មថ្នាំជក់ ឬស្ថាប័នណាមួយដែលធ្វើការបំរើផលប្រយោជន៍ឧស្សាហកម្មថ្នាំជក់ ជាសមាជិកនៃគណៈប្រតិភូ ក្នុងកិច្ចប្រជុំសន្និសីទភាគី គណៈកម្មការ ឬក្រុមផ្ដល់យោបល់ដទៃទៀត ដែលត្រូវបានបង្កើតឡើងដើម្បីសំរបសំរួល ដល់ការសំរេចចិត្តរបស់សន្និសីទភាគី។

៤.១០ ភាគីទាំងឡាយមិនគួរអនុញ្ញាឱ្យមន្ត្រី ឬនិយោជិកណាម្នាក់ របស់រដ្ឋាភិបាល ឬរបស់អង្គភាពពាក់កណ្ដាលរដ្ឋាភិបាល ទទួលយកជំនូនជាប្រាក់ ជាអំណោយឬសេវាកម្ម រូបិយប័ណ្ណឬវត្ថុប្រហាក់ប្រហែល ពីឧស្សាហកម្មថ្នាំជក់ឡើយ។

៤.១១ ដោយផ្អែកទៅលើច្បាប់ជាតិ និងគោលការណ៍រដ្ឋធម្មនុញ្ញ ភាគីទាំងឡាយគួរមានវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីហាមឃាត់ការឧបត្ថម្ភរបស់ឧស្សាហកម្មថ្នាំជក់ ឬស្ថាប័នដែលធ្វើការបំរើផលប្រយោជន៍របស់ឧស្សាហកម្មថ្នាំជក់ ដល់គណៈបក្ស បេក្ខជន ឬយុទ្ធនាការនយោបាយ ឬដើម្បីទាមទារឱ្យមានការបង្ហាញទាំងស្រុងការឧបត្ថម្ភទាំងនេះ ដល់សាធារណជន។

## (៥) ទាមទារព័ត៌មានដែលផ្ដល់ដោយឧស្សាហកម្មថ្នាំជក់ មានតម្លាភាព និងត្រឹមត្រូវ។

២៤. ដើម្បីឱ្យមានប្រសិទ្ធភាព នូវវិធានការទប់ស្កាត់ការជ្រៀតជ្រែករបស់ឧស្សាហកម្ម ប្រឆាំងនឹងគោលនយោបាយសុខភាពសាធារណៈ ភាគីទាំងឡាយត្រូវការព័ត៌មានអំពីសកម្មភាព និងការប្រព្រឹត្តរបស់ឧស្សាហកម្មថ្នាំជក់ ដើម្បីធានាថា ឧស្សាហកម្មថ្នាំជក់ប្រតិបត្តិដោយមានតម្លាភាព។ មាត្រា ១២ នៃអនុសញ្ញា ទាមទារឱ្យភាគីទាំងឡាយ បង្កលក្ខណៈឱ្យសាធារណជន ទទួលបានព័ត៌មានទាំងនេះ ស្របទៅតាម ច្បាប់ជាតិ។

២៥. មាត្រា ២០.៤ នៃអនុសញ្ញា ទាមទារឱ្យភាគីទាំងឡាយ លើកកំពស់ និងសំរបសំរួលការផ្លាស់ប្ដូរព័ត៌មានទៅវិញទៅមក អំពីការប្រព្រឹត្តរបស់ឧស្សាហកម្មថ្នាំជក់ និងការដាំថ្នាំជក់។ ដោយផ្អែកលើមាត្រា ២០.៤(គ) នៃអនុសញ្ញា ភាគីនីមួយៗគួរខ្នះខ្នែងសហការជាមួយអង្គការអន្តរជាតិដែលមានសមត្ថភាព ដើម្បីបង្កើតជាបណ្ដើរៗ និងរក្សាប្រព័ន្ធសកលមួយដើម្បីប្រមូល និងចែកចាយជាទៀងទាត់ ព័ត៌មានស្ដីពី

ផលិតកម្ម និងការផលិតថ្នាំជក់ ព្រមទាំងសកម្មភាពទាំងឡាយរបស់ឧស្សាហកម្មថ្នាំជក់ ដែលជះឥទ្ធិពលទៅលើអនុសញ្ញា និងសកម្មភាពជាតិត្រួតពិនិត្យថ្នាំជក់។

**អនុសាសន៍**

៥.១ ភាគីទាំងឡាយ គួរតែផ្តួចផ្តើម និងអនុវត្តវិធានការទាំងឡាយ ដើម្បីធានាថា ការប្រតិបត្តិ និងសកម្មភាពទាំងអស់ របស់ឧស្សាហកម្មថ្នាំជក់ មានតម្លាភាព។

៥.២ ភាគីទាំងឡាយ គួរទាមទារឱ្យឧស្សាហកម្មថ្នាំជក់ និងស្ថាប័នដែលធ្វើការបំរើផលប្រយោជន៍ឧស្សាហកម្មថ្នាំជក់ ផ្ញើព័ត៌មានស្តីពីផលិតកម្ម ការផលិតថ្នាំជក់ ភាគរយទីផ្សារ ការចំណាយទៅលើការស្វែងរកទីផ្សារ ប្រាក់ចំណូល និងសកម្មភាពដទៃទៀត រួមមាន សកម្មភាពបញ្ចុះបញ្ចូលឧបត្ថម្ភ និងសកម្មភាពដទៃទៀតដែលមិនបានហាមឃាត់ ឬមិនទាន់ហាមឃាត់ ដោយមាត្រា ១៣ នៃអនុសញ្ញា។

៥.៣ ភាគីទាំងឡាយ គួរទាមទារវិន័យក្នុងការបង្ហាញជាសាធារណៈ ឬចុះបញ្ជីអង្គការរបស់ឧស្សាហកម្មថ្នាំជក់ អង្គការដែលចំណុះឱ្យឧស្សាហកម្មថ្នាំជក់ និងបុគ្គលដែលធ្វើការតំណាងឱ្យឧស្សាហកម្មថ្នាំជក់ រួមទាំងអ្នកបញ្ចុះបញ្ចូលផងដែរ។

៥.៤ ភាគីទាំងឡាយ គួរតែដាក់ទោសបញ្ញត្តិចាំបាច់ ទៅលើឧស្សាហកម្មថ្នាំជក់ ក្នុងករណីដែលឧស្សាហកម្មថ្នាំជក់ផ្តល់នូវព័ត៌មានមិនពិត ឬបំភាន់ព័ត៌មាន ស្របទៅតាមច្បាប់ជាតិ។

៥.៥ ភាគីទាំងឡាយ គួរអនុម័ត និងអនុវត្តឱ្យមានប្រសិទ្ធភាព នូវវិធានការបញ្ញត្តិ ប្រតិបត្តិ រដ្ឋបាល និងតុលាការ ដើម្បីធានាឱ្យសាធារណជន ទទួលបានព័ត៌មានដ៏ទូលំទូលាយ ស្តីពីសកម្មភាពរបស់ឧស្សាហកម្មថ្នាំជក់ ដែលទាក់ទងទៅនឹងគោលបំណងរបស់អនុសញ្ញា ស្របទៅនឹងមាត្រា ១២(គ) នៃអនុសញ្ញា។

**(៦) ប្រែក្លាយជាមិនធម្មតា និងដាក់កំរិតតាមដែលអាចធ្វើបាន សកម្មភាពដែលឧស្សាហកម្មថ្នាំជក់ហៅថា "ការទទួលខុសត្រូវចំពោះសង្គម" ដោយរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម សកម្មភាពដែល ហៅថា "ការទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុន"។**

២៦. ឧស្សាហកម្មថ្នាំជក់រៀបចំការទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុន ដើម្បីបង្ហាញនូវរូបភាពល្អក្រុមហ៊ុនរបស់ខ្លួន ដែលផលិត និងលក់នូវផលិតផលដែលបណ្តាលឱ្យអ្នកប្រើប្រាស់ស្លាប់ ឬដើម្បីជ្រៀតជ្រែកប្រឆាំងនឹងការបង្កើត និងអនុវត្តន៍គោលនយោបាយសុខភាពសាធារណៈ។ សកម្មភាពដែលឧស្សាហកម្មថ្នាំជក់ខ្លួនឯងហៅថា "ការទទួលខុសត្រូវចំពោះសង្គម" ដែលមានគោលបំណងជំរុញឱ្យមានការប្រើប្រាស់ថ្នាំជក់ គឺជាយុទ្ធសាស្ត្រទីផ្សារ និងទំនាក់ទំនងសាធារណៈ ដែលអនុសញ្ញានេះ ផ្តល់និយមន័យថា

ជាការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ផលិតផលថ្នាំជក់ និងការឧបត្ថម្ភកម្មវិធីរបស់ឧស្សាហកម្ម ថ្នាំជក់ ។

២៧. ការទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុន របស់ឧស្សាហកម្មថ្នាំជក់ គឺជាការផ្ទុយទៅវិញ ព្រោះមុខងារសំខាន់របស់ឧស្សាហកម្មថ្នាំជក់ មានទំនាស់ជាមួយនឹងគោលដៅរបស់គោលនយោបាយសុខភាពសាធារណៈទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ ។

**អនុសាសន៍**

៦.១ ភាគីទាំងឡាយ គួរធានាថា គ្រប់ផ្នែកទាំងអស់របស់រដ្ឋាភិបាល និងរបស់សាធារណៈ បានទទួល និងយល់ដឹងអំពីគោលបំណង និងទំហំពិតប្រាកដ នៃសកម្មភាពទទួលខុសត្រូវចំពោះសង្គមរបស់ឧស្សាហកម្មថ្នាំជក់ ។

៦.២ ភាគីទាំងឡាយ មិនគួរព្រមព្រៀង គាំទ្រ បង្កើតភាពជាដៃគូ ឬចូលរួមក្នុងសកម្មភាពការទទួលខុសត្រូវចំពោះសង្គម របស់ឧស្សាហកម្មថ្នាំជក់ឡើយ ។

៦.៣ ភាគីទាំងឡាយ មិនគួរអនុញ្ញាតឱ្យមានការបង្ហាញជាសាធារណៈ ដោយឧស្សាហកម្មថ្នាំជក់ ឬដោយបុគ្គលតំណាង ស្តីពីសកម្មភាពទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុន ឬអំពីចំណាយសំរាប់សកម្មភាពទាំងនោះ លើកលែងតែនៅពេលដែលមានការទាមទារដោយផ្លូវច្បាប់ ឱ្យរាយការណ៍អំពីចំណាយទាំងនោះ ដូចជាក្នុងរបាយការណ៍ប្រចាំឆ្នាំជាដើម ។

៦.៤ ភាគីទាំងឡាយមិនគួរអនុញ្ញាតឱ្យផ្នែកណាមួយនៃរដ្ឋាភិបាល ឬផ្នែកសាធារណៈ ទទួលយកនូវការឧបត្ថម្ភផ្នែកនយោបាយ សង្គម ហិរញ្ញវត្ថុ អប់រំ សហគមន៍ និងការឧបត្ថម្ភដទៃទៀតពីឧស្សាហកម្មថ្នាំជក់ ឬពីស្ថាប័នដែលធ្វើការបំរើផលប្រយោជន៍ឧស្សាហកម្មថ្នាំជក់ លើកលែងតែសំណងជាប្រាក់តាមផ្លូវច្បាប់ ឬដោយកិច្ចព្រមព្រៀងផ្លូវច្បាប់ ។

**(៧) មិនត្រូវផ្តល់ការប្រព្រឹត្តដោយចូលចិត្ត ចំពោះឧស្សាហកម្មថ្នាំជក់ទេ ។**

២៨. រដ្ឋាភិបាលខ្លះលើកទឹកចិត្តឱ្យមានការវិនិយោគទុនដោយឧស្សាហកម្មថ្នាំជក់ រហូតដល់ទំនុកបំរុងដោយប្រាក់ ចំពោះឧស្សាហកម្មទាំងនោះ ដូចជាផ្តល់ការរួចពន្ធខ្លះ ឬទាំងស្រុង បើមិនដូចនេះទេ ដោយផ្លូវច្បាប់ ។

២៩. ដោយមិនធ្វើឱ្យខូចខាតដល់សិទ្ធិអធិបតេយ្យ ដើម្បីកំណត់ និងបង្កើតគោលនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងពន្ធដារ ភាគីទាំងឡាយគួររក្សាការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះការត្រួតពិនិត្យថ្នាំជក់ ។

**អនុសាសន៍**

៧.១ ភាគីទាំងឡាយមិនគួរផ្តល់ការលើកទឹកចិត្ត អភ័យឯកសិទ្ធិ ឬផលប្រយោជន៍ដល់ឧស្សាហកម្មថ្នាំជក់ ដើម្បីបង្កើត ឬដំណើរការមុខជំនួញរបស់ខ្លួនឡើយ ។

៧.២ ភាគីទាំងឡាយ ដែលគ្មានឧស្សាហកម្មថ្នាំជក់របស់រដ្ឋ មិនគួរដាក់វិនិយោគទុនលើឧស្សាហកម្មថ្នាំជក់ និងការប្រថុយប្រថានប្រហាក់ប្រហែលគ្នានេះទេ។ ភាគីទាំងឡាយដែលមានឧស្សាហកម្មថ្នាំជក់ជារបស់រដ្ឋ គួរធានាថា ការវិនិយោគទុនណាមួយនៅក្នុងឧស្សាហកម្មថ្នាំជក់ មិនបានរាំងស្កាត់ភាគីទាំងនោះ ក្នុងការអនុវត្តន៍ដោយពេញលេញនូវអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់។

៧.៣ ភាគីទាំងឡាយ មិនគួរផ្តល់ការរួចពន្ធពិសេសណាមួយ ចំពោះឧស្សាហកម្មថ្នាំជក់ទេ។

**(៨) ប្រព្រឹត្តដូចគ្នា ចំពោះឧស្សាហកម្មថ្នាំជក់របស់រដ្ឋ និងឧស្សាហកម្មថ្នាំជក់ដទៃទៀត។**

៣០. ឧស្សាហកម្មថ្នាំជក់ អាចជារបស់រដ្ឋាភិបាល ឬមិនមែនជារបស់រដ្ឋាភិបាល ឬរួមគ្នា។ គោលការណ៍ណែនាំទាំងនេះ អនុវត្តចំពោះគ្រប់ឧស្សាហកម្មថ្នាំជក់ ដោយមិនគិតពីកម្មសិទ្ធិភាពទេ។

**អនុសាសន៍**

៨.១ ភាគីទាំងឡាយ គួរធានាថា ឧស្សាហកម្មថ្នាំជក់របស់រដ្ឋ ត្រូវបានអនុវត្តដូចគ្នា ទៅនឹងឧស្សាហកម្មថ្នាំជក់ដទៃទៀត ទាក់ទិនទៅនឹងការបង្កើត និងការអនុវត្តន៍គោលនយោបាយត្រួតពិនិត្យថ្នាំជក់។

៨.២ ភាគីទាំងឡាយ គួរធានាថា ការបង្កើត និងអនុវត្តន៍គោលនយោបាយត្រួតពិនិត្យថ្នាំជក់ ចែកដាច់ពីការត្រួតត្រា ឬគ្រប់គ្រងឧស្សាហកម្មថ្នាំជក់។

៨.៣ ភាគីទាំងឡាយ គួរធានាថា តំណាងរបស់ឧស្សាហកម្មថ្នាំជក់របស់រដ្ឋ មិនអាចក្លាយជាសមាជិកនៃគណៈប្រតិភូទៅកាន់កិច្ចប្រជុំនៃសន្និសីទភាគី ក្រុមផ្តល់យោបល់ ឬគណៈកម្មការណាមួយដែលត្រូវបានបង្កើតឡើងដើម្បីសំរបសំរួលការសំរេចចិត្តរបស់សន្និសីទភាគី។

# ការពង្រឹង និងការតាមដានការអនុវត្តន៍

## ការពង្រឹងការអនុវត្តន៍

៣១. ភាគីទាំងឡាយ គួរបង្កើតយន្តការពង្រឹង ឬប្រើប្រាស់យន្តការពង្រឹងដែលមានស្រាប់ តាមដែលអាចធ្វើទៅបាន ដើម្បីបំពេញកាតព្វកិច្ចមាត្រាទី ៥.៣ នៃអនុសញ្ញា និងគោលការណ៍ណែនាំទាំងនេះ។

## តាមដាន ការអនុវត្តន៍មាត្រា ៥.៣ នៃអនុសញ្ញា និងគោលការណ៍ណែនាំទាំងនេះ

៣២. តាមដានការអនុវត្តន៍មាត្រា ៥.៣ នៃអនុសញ្ញា និងគោលការណ៍ណែនាំទាំងនេះ មានសារសំខាន់ ដើម្បីធានានូវការផ្តួចផ្តើម និងអនុវត្តន៍ឱ្យមានប្រសិទ្ធភាពគោលនយោបាយត្រួតពិនិត្យថ្នាំជក់។ ការតាមដាននេះ គួរពាក់ព័ន្ធការតាមដានឧស្សាហកម្មថ្នាំជក់ ហើយគំរូ និងធនធានដែលមានស្រាប់ គួរត្រូវបានប្រើ

ប្រាស់ ដូចជាទិន្នន័យស្តីពីការតាមដានឧស្សាហកម្មថ្នាំជក់ របស់កម្មវិធីផ្តួចផ្តើមគ្មានថ្នាំជក់ របស់អង្គការសុខភាពពិភពលោក ។

៣៣. អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកនៃសង្គមស៊ីវិលដទៃទៀត ដែលមិនចំណុះឱ្យឧស្សាហកម្មថ្នាំជក់ អាចមានតួនាទីសំខាន់នៅក្នុងការតាមដានសកម្មភាពរបស់ឧស្សាហកម្មថ្នាំជក់ ។

៣៤. ក្រមប្រតិបត្តិ ឬបទបញ្ជារបស់បុគ្គលិក របស់គ្រប់ផ្នែកនៃរដ្ឋាភិបាល គួរបញ្ចូល "មុខងារផ្តុំកញ្ចែ" ដោយការពារអ្នកផ្លុំកញ្ចែឱ្យបានគ្រប់គ្រាន់ ។ លើសពីនេះទៀត ភាគីទាំងឡាយ គួរត្រូវបានលើកទឹកចិត្ត ឱ្យប្រើប្រាស់ និងពង្រឹងយន្តការទាំងឡាយ ដើម្បីធានានូវការប្រតិបត្តិតាមគោលការណ៍ណែនាំ ដូចជា លទ្ធភាពប្តឹងករណីរំលោភបំពានទៅតុលាការ និងប្រើប្រាស់នីតិវិធីតុលការ ។

## កិច្ចសហប្រតិបត្តិអន្តរជាតិ និងការពិនិត្យឡើងវិញគោលការណ៍ទាំងនោះ

៣៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ មានសារសំខាន់ដើម្បីធ្វើឱ្យមានការរីកចំរើនដល់ការរាំងស្កាត់ការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ ប្រឆាំងនឹងការតាក់តែងគោលនយោបាយសុខភាពសាធារណៈស្តីពីការត្រួតពិនិត្យថ្នាំជក់ ។ មាត្រា ២៤.៤ នៃអនុសញ្ញា ផ្តល់នូវមូលដ្ឋានក្នុងការប្រមូល និងផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ ទាក់ទិនទៅនឹងការប្រតិបត្តិ ដោយរាប់បញ្ចូល និងបរិយាយអំពីសេចក្តីត្រូវការពិសេសរបស់ភាគីទាំងឡាយនៃប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីទាំងឡាយ ដែលមានសេដ្ឋកិច្ចអន្តរកាល ។

៣៦. កិច្ចប្រឹងប្រែងទាំងឡាយ ត្រូវបានគេធ្វើឡើងដើម្បីសំរបសំរួលការប្រមូល និងចែកចាយបទពិសោធន៍ជាតិ និងអន្តរជាតិ ស្តីពីយុទ្ធសាស្ត្រ និងកលល្បិចប្រើប្រាស់ដោយឧស្សាហកម្មថ្នាំជក់ និងដើម្បីតាមដានសកម្មភាពរបស់ឧស្សាហកម្មថ្នាំជក់ ។ ភាគីទាំងឡាយ នឹងទទួលបានផលប្រយោជន៍ក្នុងការចែករំលែកជំនាញផ្លូវច្បាប់សំខាន់ៗ ក្នុងការប្រឆាំងទៅនឹងយុទ្ធសាស្ត្រ របស់ឧស្សាហកម្មថ្នាំជក់ ។ មាត្រា ២១.៤ នៃអនុសញ្ញា ផ្តល់យោបល់ថា ការផ្លាស់ប្តូរព័ត៌មាន គួរតែស្របទៅនឹងច្បាប់ជាតិ ស្តីពីការសំងាត់និភាពឯកជន ។

## អនុសាសន៍

៣៧. ដោយសារយុទ្ធសាស្ត្រ និងកលល្បិចរបស់ឧស្សាហកម្មថ្នាំជក់ មានការវិវត្តន៍ជានិច្ច គោលការណ៍ណែនាំទាំងនេះ គួរពិនិត្យ និងកែសំរួលឡើងវិញ តាមកាលកំណត់ ដើម្បីធានាថា គោលការណ៍ណែនាំទាំងនេះ នៅតែផ្តល់ការណែនាំប្រកបដោយប្រសិទ្ធភាព ចំពោះភាគីទាំងឡាយ នៅក្នុងការការពារគោលនយោបាយសុខភាពសាធារណៈស្តីពីការត្រួតពិនិត្យថ្នាំជក់របស់ខ្លួន ប្រឆាំងនឹងការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ ។

៣៨. ភាគីទាំងឡាយ ដែលរាយការណ៍តាមបែបបទរបាយការណ៍ដែលមានស្រាប់របស់អនុសញ្ញា គួរផ្តល់ព័ត៌មានស្តីពីផលិតកម្ម និងការផលិតថ្នាំជក់ ព្រមទាំងសកម្មភាពទាំងឡាយរបស់ឧស្សាហកម្មថ្នាំជក់

ដែលប៉ះពាល់ដល់អនុសញ្ញា ឬសកម្មភាពជាតិត្រួតពិនិត្យថ្នាំជក់។ ដើម្បីសំរបសំរួលការផ្លាស់ប្តូរនេះ លេខាធិការដ្ឋាននៃអនុសញ្ញា គួរធានាថា ខសំខាន់ៗនៃគោលការណ៍ណែនាំទាំងនេះ មានបញ្ចូលទៅក្នុងបែបបទរបាយការណ៍ ក្នុងដំណាក់កាលបន្ទាប់ ដែលសន្និសីទភាគីនឹងអនុម័តជាបណ្តើរៗ សំរាប់ការប្រើប្រាស់ដោយភាគីទាំងឡាយ។

៣៩. ដោយមើលឃើញនូវសារសំខាន់ដ៏លើសលប់ នៃការរាំងស្កាត់ការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ប្រឆាំងនឹងសុខភាពសាធារណៈណាមួយ ទាក់ទិនទៅនឹងការត្រួតពិនិត្យថ្នាំជក់ សន្និសីទភាគី នឹងពិចារណាអំពីសេចក្តីត្រូវការបង្កើតពិធីការដើម្បីអនុវត្តមាត្រា ៥.៣ នៃអនុសញ្ញា។